**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**លេខ:....................សអយ**

*រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ២០០៧*

# សារាចរណែនាំ

## ស្តីពី

## ការងារសមាហរណកម្ម និងតាមដាន ក្រុមជនរងគ្រោះ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល

សារាចរណែនាំនេះ មានគោលបំណងពង្រឹងពង្រីក ការងារសមាហរណកម្ម និង តាមដាន ក្រុមជនរងគ្រោះ ដែលបានស្នាក់នៅបណ្តោះអាសន្ន ឬ យូរអង្វែងរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ។

ដើម្បីបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងការអនុវត្តកម្មវិធី ឬគម្រោងនានារបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល និងដើម្បីរួមចំណែកទប់ស្កាត់កាត់បន្ថយភាពរងគ្រោះ របស់ប្រជាជនស្របតាមការងារអាទិភាព របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងណែនាំការអនុវត្តការងារសមាហរណកម្ម និង តាមដានក្រុមជនរងគ្រោះ ដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដូចខាងក្រោម :-

## ១-ប្រព័ន្ធការងារគ្រប់គ្រងករណី :

មជ្ឈមណ្ឌលរបស់រដ្ឋ និងមជ្ឈមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តតាមដំណាក់កាលទាំងបួន នៃដំណើរការធ្វើសមាហរណកម្ម និងតាមដានគឺ : ដំណាក់កាលមុនធ្វើសមាហរណកម្ម ដំណាក់ធ្វើសមាហរណកម្ម ការតាមដានប្រភេទទី១ និងការតាមដានប្រភេទទី ២ :

### ១-១-ដំណាក់កាលមុនពេលសមាហរណកម្ម :

ដំណាក់កាលនេះ ត្រូវមានសកម្មភាពសំខាន់ចំនួន ៣ ដូចតទៅ :

**ទី១ :** មុនពេលធ្វើសមាហរណកម្ម ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ត្រូវចាត់ការឱ្យមន្ត្រីសង្គមកិច្ចជួយដល់មជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាលក្នុងការស្វែងរកគ្រួសាររបស់ជនដែលត្រូវធ្វើសមាហរណកម្ម ។

**ទី២ :** ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ត្រូវចាត់ការឱ្យមន្ត្រីសង្គមកិច្ច ធ្វើការប៉ាន់ប្រមាណគ្រួសារ និងសហគមន៍ ព្រមទាំងជួយដល់ដំណើរផ្សះផ្សាជាមួយ នឹងគ្រួសាររបស់ជនដែលត្រូវធ្វើសមាហរណកម្ម ។

**ទី៣ :** ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ត្រូវចាត់ការឱ្យមន្ត្រីសង្គមកិច្ច រៀបចំផែនការគាំទ្រផ្នែកសង្គមកិច្ច និងឈានទៅរកការធ្វើសមាហរណកម្មជនរងគ្រោះតាមជំរើសពីរយ៉ាងដូចខាងក្រោម:-

***ក - ជំរើសទី ១***

**ជំហ៊ានទី១:** មជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើទំនាក់ទំនងជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ជនបង្គោលទទួលបន្ទុកការងារសមាហរណកម្ម និង សុំឱ្យពួកគេកំណត់កន្លែងជួបគ្នា ( ជាទូទៅនៅផ្ទះរបស់ប្រធានភូមិ ) និងកាលបរិច្ឆេទសម្រាប់ធ្វើការស្វែងរកគ្រួសារ យ៉ាងហោចណាស់ ០៧ ថ្ងៃ មុនពេលចុះស្វែងរកគ្រួសារ ។

**ជំហ៊ានទី២:** ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវទំនាក់ទំនងជាមួយមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ដើម្បីកំណត់កាលបរិច្ឆេទសម្រាប់ស្វែងរកគ្រួសារ ហើយបន្ទាប់មក ជនបង្គោលត្រូវបញ្ជាក់ពីកាលបរិច្ឆេទនេះជាមួយអង្គការមិនមែនរដ្ឋាភិបាល ។

**ជំហ៊ានទី៣:** មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ត្រូវជួបជាមួយបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល នៅផ្ទះប្រធានភូមិ ។

**ជំហ៊ានទី៤:** មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើការស្វែងរកគ្រួសាររួមគ្នា ។

- **កំណត់សំគាល់ :** *នៅពេលមិនស្គាល់ឈ្មោះភូមិច្បាស់ ការជួបគ្នានេះអាចរៀបចំនៅសាលាឃុំ សង្កាត់ ។*

**ជំហ៊ានទី៥:** មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើដំណើររួមគ្នាទៅផ្ទះរបស់ជនដែលត្រូវធ្វើសមាហរណកម្ម ហើយចាប់ផ្តើមធ្វើការប៉ាន់ប្រមាណគ្រួសារ ដោយប្រើទម្រង់ស្វែងរកគ្រួសារ និងទម្រង់ប៉ាន់ប្រមាណគ្រួសារ ។

**ជំហ៊ានទី៦:** មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើដំណើររួមគ្នាទៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ឬផ្ទះរបស់ប្រធានភូមិ ដើម្បីប្រជុំពិភាក្សាសម្រេច :-

- តើអាចធ្វើសមាហរណកម្មជនរងគ្រោះបានដែរឬទេ ?
- តើគេត្រូវការ ការគាំទ្រផ្នែកសង្គមកិច្ចបន្ថែមទៀតឬទេ ? ដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្គត់ផ្គង់ស្បៀងអាហារ ឥណទាន ដើម្បីបង្កើនប្រាក់ចំណូល ការបញ្ជូនឱ្យចូលរៀនតាមសាលា ការពិគ្រោះយោបល់ ការថែទាំសុខភាព ការគាំទ្រផ្នែកច្បាប់ ។ ល ។
- ធ្វើផែនការ ដើម្បីអនុវត្តការសម្រេចចិត្តរបស់ជនដែលត្រូវធ្វើសមាហរណកម្ម ឬ គ្រួសារដោយប្រើប្រាស់ទម្រង់សេវាគាំទ្រផ្នែកសង្គមកិច្ច ។

### *ខ - ជំរើសទី ២*

**ជំហ៊ានទី១:** មជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ត្រូវទំនាក់ទំនងជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង ជនបង្គោលទទួលបន្ទុកការងារសមាហរណកម្ម សុំជំនួយស្វែងរកគ្រួសារ របស់ជនដែលត្រូវធ្វើសមាហរណកម្ម។ មជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវផ្តល់ព័ត៌មានជាមូលដ្ឋាន

សម្រាប់ការស្វែងរកគ្រួសារដល់ជនបង្គោលទទួលបន្ទុកការងារសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ហើយបន្ទាប់មកជនបង្គោល ត្រូវបញ្ជូនព័ត៌មាននេះទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ។

**ជំហ៊ានទី២:ក.** មន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ធ្វើការស្វែងរកគ្រួសារ ។ នៅពេលស្វែងរកគ្រួសារជនដែលត្រូវធ្វើសមាហរណកម្មឃើញហើយ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ត្រូវរាយការណ៍ជូនជនបង្គោលទទួលបន្ទុកការងារសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ។

**ជំហ៊ានទី២:ខ.** បន្ទាប់ពីរយៈពេល ១៥ ថ្ងៃ មជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ត្រូវទំនាក់ទំនងទៅជនបង្គោលទទួលបន្ទុកការងារសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ដោយផ្ទាល់ ដើម្បីទទួលបាននូវព័ត៌មានដែលពាក់ព័ន្ធ និងដើម្បីរៀបចំការចុះប៉ាន់ប្រមាណគ្រួសារជាលើកទី១។ ជនបង្គោលទទួលបន្ទុកការងារសមាហរណកម្ម ត្រូវបញ្ជូនព័ត៌មានអំពីការចុះប៉ាន់ប្រមាណគ្រួសាររួមគ្នានេះ ទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ។

**ជំហ៊ានទី៣:** មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាលត្រូវជួបគ្នានៅផ្ទះប្រធានភូមិ ហើយធ្វើដំណើររួមគ្នាទៅផ្ទះរបស់ជនដែលត្រូវធ្វើសមាហរណកម្ម ។

**ជំហ៊ានទី៤:** មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើការប៉ាន់ប្រមាណគ្រួសារ ដោយប្រើទម្រង់ប៉ាន់ប្រមាណគ្រួសារ ។

**ជំហ៊ានទី៥:** មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវធ្វើដំណើររួមគ្នាទៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ឬ ផ្ទះរបស់ប្រធានភូមិ ដើម្បីប្រជុំពិភាក្សាសម្រេច :-

- តើអាចធ្វើសមាហរណកម្មជនរងគ្រោះបានដែរឬទេ ?
- តើគេត្រូវការ ការគាំទ្រផ្នែកសង្គមកិច្ចបន្ថែមទៀតឬទេ ? ដូចជាការបណ្តុះបណ្តាលវិជ្ជាជីវៈ ការផ្គត់ផ្គង់ស្បៀងអាហារ ឥណទាន ដើម្បីបង្កើនប្រាក់ចំណូល ការបញ្ជូនឱ្យចូលរៀនតាមសាលា ការពិគ្រោះយោបល់ សុខភាព ការគាំទ្រផ្នែកច្បាប់ ។ល។
- ធ្វើផែនការ ដើម្បីអនុវត្តការសម្រេចចិត្តរបស់ជនដែលត្រូវធ្វើសមាហរណកម្ម ឬ គ្រួសារដោយប្រើប្រាស់ទម្រង់សេវាគាំទ្រផ្នែកសង្គមកិច្ច។

**ជំហ៊ានទី៦:** មុនពេលធ្វើសមាហរណកម្ម មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ត្រូវចុះទៅគ្រួសារជនដែលត្រូវធ្វើសមាហរណកម្មយ៉ាងតិចបំផុត ០២ដង ដើម្បីពិភាក្សាអំពីការផ្សះផ្សារវាងគ្រួសារ និងសហគមន៍ ។

សមាហរណកម្មគ្រួសារ អាចពិចារណាធ្វើទៅបានលុះត្រាតែការចុះផ្សះផ្សាបង្ហាញយ៉ាងច្បាស់ថា គ្រួសារបានស្វាគមន៍ការវិលត្រឡប់របស់ជនដែលត្រូវធ្វើសមាហរណកម្ម ហើយជននោះនឹងមានសុវត្ថិភាព និងបានទទួលការយកចិត្តទុកដាក់ ។

មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវធានាថាលទ្ធផល នៃការចុះទៅគ្រួសារ ត្រូវលើកយកមកពិភាក្សាជាមួយជនដែលត្រូវធ្វើសមាហរណកម្ម ហើយជននោះចូលរួមនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត អំពីសមាហរណកម្មដែលអាចធ្វើបាន ។

ប្រសិនបើសមាហរណកម្មជាមួយគ្រួសារផ្ទាល់របស់ជនដែលត្រូវធ្វើសមាហរណកម្ម មិនអាចធ្វើបានទេ ហើយប្រសិនបើជននោះយល់ព្រមមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ប្រធានភូមិ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ត្រូវរកលទ្ធភាពធ្វើសមាហរណកម្មជននោះ ទៅជាមួយគ្រួសារសាច់ញាតិ ឬ គ្រួសារធម៌វិញ ។

ការទុកដាក់ជនដែលត្រូវធ្វើសមាហរណកម្មឱ្យទទួលការថែទាំយូរអង្វែងនៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ឬមជ្ឈមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាលនានា អាចធ្វើទៅបានតែក្នុងករណីដែលមិនអាចធ្វើសមាហរណកម្មជននោះ ជាមួយគ្រួសារបង្កើត គ្រួសារសាច់ញាតិ គ្រួសារធម៌ ឬ គ្រួសារចិញ្ចឹម ។

### ១-២-ដំណាក់កាលធ្វើសមាហរណកម្ម :

**ជំហ៊ានទី១:** មជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវទំនាក់ទំនងជាមួយជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ដើម្បីបញ្ជាក់អំពីទីកន្លែង និងកាលបរិច្ឆេទ ធ្វើសមាហរណកម្មជនដែលត្រូវធ្វើសមាហរណកម្ម ។ ការទំនាក់ទំនងនេះធ្វើឡើងយ៉ាងហោចណាស់ ០៧ថ្ងៃ មុនពេលធ្វើសមាហរណកម្មជាក់ស្តែង។

**ជំហ៊ានទី២:** ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវបញ្ជាក់អំពី កាលបរិច្ឆេទ នៃការធ្វើសមាហរណកម្ម ដល់មជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ។

**ជំហ៊ានទី៣:** មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ត្រូវជួបជាមួយបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល និងជនដែលត្រូវធ្វើសមាហរណកម្មនៅផ្ទះប្រធានភូមិ ។

**ជំហ៊ានទី៤:** មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ បុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល និងជនដែលត្រូវធ្វើសមាហរណកម្មធ្វើដំណើររួមគ្នាទៅផ្ទះជនដែលត្រូវធ្វើសមាហរណកម្ម ។

**ជំហ៊ានទី៥:** ប្រសិនបើមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ បុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល និងជនដែលត្រូវធ្វើសមាហរណកម្ម ជឿជាក់លើការប្តេជ្ញាចិត្តរបស់គ្រួសារ ក្នុងការស្វាគមន៍ ការវិលត្រឡប់របស់ជនដែលត្រូវធ្វើសមាហរណកម្ម និងក្នុងការផ្តល់ការថែទាំ និងការការពារដល់ជននោះ កិច្ចសន្យាសមាហរណកម្មជាផ្លូវការ នឹងត្រូវចុះហត្ថលេខា ។ កិច្ចសន្យាមានចំនួនបីច្បាប់ដោយត្រូវចែកជូន ទៅគ្រួសារជនដែលត្រូវធ្វើសមាហរណកម្ម ចំនួន ០១ច្បាប់ មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ចំនួន ០១ច្បាប់ និងជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ចំនួន ០១ច្បាប់ ។

### ១-៣-ការតាមដានប្រភេទទី១:

ការតាមដានប្រភេទទី ១ គឺជារយៈពេលដែលផែនការគាំទ្រផ្នែកសង្គមកិច្ចត្រូវបានអនុវត្ត ហើយសេវានានានៅក្នុងផែនការនេះត្រូវបានផ្តល់ឱ្យជនដែលត្រូវធ្វើសមាហរណកម្ម ។ នៅកំឡុងពេលចុះតាមដានប្រភេទទី ១នេះ មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ និងបុគ្គលិក

មជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ធ្វើដំណើរទៅផ្ទះជនដែលត្រូវធ្វើសមាហរណកម្មរួមគ្នា ដើម្បីធ្វើការចុះពិនិត្យ និងតាមដាន ដល់ផ្ទះជនដែលត្រូវធ្វើសមាហរណកម្ម។ ចំនួននៃការចុះពិនិត្យ និងតាមដានរួមគ្នានេះត្រូវកំណត់នៅតាមករណីនីមួយៗ ដែលបានព្រមព្រៀងគ្នារវាងមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ។ ការចុះពិនិត្យ និងតាមដាន ដល់ផ្ទះជនដែលត្រូវធ្វើសមាហរណកម្មជាលើកទី១ ត្រូវធ្វើឡើងនៅរយៈពេល ០២សប្តាហ៍ ក្រោយពេលធ្វើសមាហរណកម្មគ្រួសារហើយចុះពិនិត្យ និងតាមដានបន្តបន្ទាប់ទៀតជាប្រចាំប៉ុន្តែយ៉ាងហោចណាស់ម្តងក្នុងមួយខែ ។ ក្នុងករណីខ្លះ ការតាមដានប្រភេទទី១ នេះអាចត្រូវគេរំលងចោលដូចជាករណីនៅតំបន់ដាច់ស្រយាល ដែលមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ខ្វះសមត្ថភាព ខ្វះថវិកា ខ្វះធនធានមនុស្សចុះតាមដាន។ ក្នុងករណីបែបនេះមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ត្រូវបន្តការងារចូលដល់ការតាមដានប្រភេទទី ២តែម្តង ។ ជំហ៊ានតាមដានប្រភេទទី១ មានដូចខាងក្រោម :

**ជំហ៊ានទី១:** ក្នុងអំឡុងពេលធ្វើសមាហរណកម្ម ឬការចុះពិនិត្យ និងតាមដានចុងក្រោយមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការចុះពិនិត្យ និងតាមដានពេលក្រោយទៀត ។ មជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវបញ្ជាក់ឱ្យបានច្បាស់ អំពីការចុះពិនិត្យ និងតាមដាននេះឱ្យបាន ០៣ ថ្ងៃមុនពេលចុះ ដោយជូនដំណឹងទៅជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ។

**ជំហ៊ានទី២:** ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវបញ្ជាក់ឱ្យបានច្បាស់ ជាមួយមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ អំពីការចុះតាមដាននេះ ។

**ជំហ៊ានទី៣:** មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវជួបគ្នាផ្ទាល់នៅផ្ទះរបស់ជនដែលត្រូវធ្វើសមាហរណកម្ម តាមកាលបរិច្ឆេទ និងពេលវេលាដែលបានកំណត់ទុក ហើយពិភាក្សាពីស្ថានភាពរបស់ជនដែលត្រូវធ្វើសមាហរណកម្មជាមួយគ្រួសារ ប្រធានភូមិ និងជនដែលត្រូវធ្វើសមាហរណកម្មផ្ទាល់នៅក្នុងជំនួបពិភាក្សា ៣ ដាច់ដោយឡែកពីគ្នាដែលអាចរក្សាការសម្ងាត់បាន ដើម្បីឱ្យពួកគេបង្ហាញអំពីអារម្មណ៍ ។

***១-៤-ការតាមដានប្រភេទទី២ :***

ការតាមដានប្រភេទទី ២ ផ្តល់ភាពទទួលខុសត្រូវទាំងស្រុងដល់មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ក្នុងការងារគ្រប់គ្រងករណី ដោយរួមទាំងការរៀបចំផែនការ និងការចុះតាមដានដល់ផ្ទះជនដែលត្រូវធ្វើសមាហរណកម្ម។ មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ត្រូវផ្តល់លទ្ធផលការងារនៅក្នុងទម្រង់ទី ៦ (ខ )ដល់មជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាថាមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាលទាំងនោះបានដឹង និងអាចទទួលបាននូវជំនួយចាំបាច់ ។ ជំហ៊ានសម្រាប់ការចុះតាមដានប្រភេទទី ២ នេះមានដូចខាងក្រោម :

**ជំហ៊ានទី១:** មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ធ្វើការតាមដានដល់ផ្ទះជនដែលត្រូវធ្វើសមាហរណកម្ម ដើម្បីធ្វើការប៉ាន់ប្រមាណអំពីស្ថានភាពរបស់ជននោះ ស្ថានភាពរបស់គ្រួសារ បញ្ហានានា និងជោគជ័យដែលសម្រេចបាននៅក្នុងជំនួបពិភាក្សា

ដាច់ដោយឡែកពីគ្នា ដើម្បីរក្សាការសម្ងាត់បាន ។ ក្នុងករណី ដែលមិនអាចធ្វើការតាមដានប្រភេទទី ១បាន មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ត្រូវចុះពិនិត្យ និងតាមដានលើកដំបូងទៅផ្ទះ របស់ជនដែលត្រូវធ្វើសមាហរណកម្ម ក្នុងរយៈពេល ០២សប្តាហ៍ ក្រោយពេលធ្វើសមាហរណកម្មគ្រួសារ ហើយត្រូវចុះពិនិត្យ និងតាមដានបន្តបន្ទាប់ទៀតជាប្រចាំ ប៉ុន្តែយ៉ាងហោចណាស់ម្តងក្នុងមួយខែ ។

**ជំហ៊ានទី២:** មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ត្រូវបំពេញទម្រង់ផ្តល់លទ្ធផលដល់មជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ហើយបញ្ជូនទម្រង់ដែលបំពេញរួចទៅជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ។

**ជំហ៊ានទី៣:** ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវបញ្ជូនទម្រង់ផ្តល់លទ្ធផលទៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មនៃនាយកដ្ឋានសុខុមាលភាពសង្គម អគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្នុងករណីចាំបាច់ និងបន្ទាន់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ត្រូវជូនដំណឹងទៅមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធដោយផ្ទាល់ ។

**ជំហ៊ានទី៤:** ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម នៃនាយកដ្ឋានសុខុមាលភាពសង្គម អគ្គនាយកដ្ឋានបច្ចេកទេស ត្រូវបញ្ជូនទម្រង់ផ្តល់លទ្ធផល (ទម្រង់ទី៦ ខ) ទៅមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធក្នុងការធ្វើសមាហរណកម្ម ជនដែលត្រូវធ្វើសមាហរណកម្ម ។

## ២-ការប្រជុំសម្របសម្រួល និង ការបិទករណី :

### *២-១-ការប្រជុំសម្របសម្រួល :*

ការប្រជុំសម្របសម្រួល មានគោលបំណងដូចខាងក្រោម :-

- ប៉ាន់ប្រមាណលើស្ថានភាពបច្ចុប្បន្នរបស់ជនដែលត្រូវធ្វើសមាហរណកម្ម ដែលត្រូវបានធ្វើសមាហរណកម្មរួចហើយ
- ពិភាក្សាលើបញ្ហានានា ដែលត្រូវប្រឈមមុខ ជាពិសេសករណីលំបាក១
- កំណត់ពីសេវាទាំងអស់ដែលបានផ្តល់ឱ្យជនដែលត្រូវធ្វើសមាហរណកម្ម តាំងពីពេលធ្វើសមាហរណកម្មរហូតដល់បច្ចុប្បន្ន
- ដោះស្រាយ និងធ្វើការសម្រេចចិត្តនានា ក្នុងការផ្តល់សេវាបន្តតាមតម្រូវការរបស់ជនដែលត្រូវធ្វើសមាហរណកម្ម
- សម្រេចបិទករណី ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបិទករណី ។

### *២-២-ការបិទករណី :*

លក្ខណៈវិនិច្ឆ័យដូចខាងក្រោម ដែលត្រូវព្រមព្រៀង ដើម្បីបិទករណី :-

***ក - ជនដែលត្រូវធ្វើសមាហរណកម្ម និង គ្រួសារមានជីវភាពនឹងនរ ( សមាហរណកម្មមានស្ថេរភាពបាន ១ ឆ្នាំ ) :***

- ទំនាក់ទំនងរវាងគ្រួសារ និងជនដែលត្រូវធ្វើសមាហរណកម្ម អាចមានសភាពនឹងនរ និងមាននិរន្តរភាព
- ស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារលើសពីកំរិតដែលអាចរស់រានបាន

- ជនដែលត្រូវធ្វើសមាហរណកម្ម បានចូលរួមក្នុងសកម្មភាពធម្មតា និងជាប្រចាំដូចជា ទៅរៀន រកប្រាក់ចំណូល (នៅក្នុងឬនៅក្រៅផ្ទះ) ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម
- ភស្តុតាងបង្ហាញថាជនដែលត្រូវធ្វើសមាហរណកម្មមានស្ថេរភាព ទាំងខាងសេដ្ឋកិច្ច និងផ្នែកចិត្តសាស្ត្រសង្គម ។

***ខ - ជនដែលត្រូវធ្វើសមាហរណកម្មបានបាត់ខ្លួន (ជនដែលត្រូវធ្វើសមាហរណកម្មបានផ្លាស់ប្តូរទីលំនៅ ហើយមិនអាចរកឃើញ) :***

- ជនដែលត្រូវធ្វើសមាហរណកម្ម បានផ្លាស់ប្តូរទីលំនៅ ហើយមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ មិនអាចរកឃើញ
- ប្រសិនបើជនដែលត្រូវធ្វើសមាហរណកម្ម បានផ្លាស់ប្តូរទីលំនៅ ហើយមន្ត្រី ស្រុក ខណ្ឌ ស្គាល់ទីលំនៅថ្មីរបស់ជនដែលត្រូវធ្វើសមាហរណកម្ម មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ នោះ ត្រូវបញ្ជូនសំណុំឯកសារករណី របស់ជនដែលត្រូវធ្វើសមាហរណកម្មនោះទៅមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ដែលមានទីលំនៅថ្មី របស់ជនដែលត្រូវធ្វើសមាហរណកម្មស្ថិតនៅ ដើម្បីធ្វើការតាមដានបន្ត។
- ប្រសិនបើមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ មិនដឹងអំពីទីលំនៅថ្មី របស់ជនដែលត្រូវធ្វើសមាហរណកម្មទេ មន្ត្រីសង្គមកិច្ច និងបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវចុះទៅសហគមន៍ដែលជនដែលត្រូវធ្វើសមាហរណកម្ម ធ្លាប់រស់នៅយ៉ាងហោចណាស់ ២ ដង ដើម្បីស្វែងរកទីលំនៅថ្មីរបស់ជនដែលត្រូវធ្វើសមាហរណកម្ម ។

***គ - គ្រួសាររបស់ជនដែលត្រូវធ្វើសមាហរណកម្មមិនគោរពកិច្ចព្រមព្រៀង :***

ជនដែលត្រូវធ្វើសមាហរណកម្ម និង គ្រួសារមិនគោរពកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខាជាមួយមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល ដែលបានធ្វើសមាហរណកម្ម ដោយមានមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ជាសាក្សី ។ ទោះបីជាករណីនេះត្រូវបានបិទក៏ដោយ មន្ត្រីសង្គមកិច្ចត្រូវចុះតាមដានស្ថានភាពរបស់ជនដែលត្រូវធ្វើសមាហរណកម្ម ទៅតាមវិសាលភាពដែលអាចធ្វើបាន។

***ឃ- ជនដែលត្រូវធ្វើសមហរណកម្ម បានរត់ចេញពីគ្រួសារ ហើយរកមិនឃើញ***

***ង- ជនដែលត្រូវធ្វើសមាហរណកម្ម បានស្លាប់បាត់បង់ជីវិត***

***ច - ជនដែលត្រូវធ្វើសមាហរណកម្ម រត់ចេញបាត់ពីមជ្ឈមណ្ឌល***

***ឆ - ជនដែលត្រូវធ្វើសមាហរណកម្ម បានរត់ចេញពីមជ្ឈមណ្ឌលសំចត***

***ជ - កំណត់សំគាល់ :***

ប្រសិនបើ ជនដែលត្រូវធ្វើសមាហរណកម្ម មិនត្រូវបានធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ប្រកបទៅដោយសេចក្តីសោមនស្សទេ ករណីនេះមិនត្រូវបិទទេ ។ ប្រសិនបើ ជនដែលត្រូវធ្វើសមាហរណកម្មកំពុងរស់នៅក្នុងមណ្ឌលថែទាំយូរអង្វែង មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ត្រូវត្រួតពិនិត្យ និងប៉ាន់ប្រមាណករណីនេះសារឡើងវិញជារៀងរាល់ ៦ ខែម្តង ។

***ឈ- ផ្សេងៗ***

## ៣-តួនាទី និង ភារកិច្ចរបស់មន្ត្រីទទួលបន្ទុកសមាហរណកម្ម និង តាមដាននៅថ្នាក់កណ្តាលថ្នាក់ខេត្ត-ក្រុង និង ថ្នាក់ស្រុក ខណ្ឌ :

### *៣-១-ថ្នាក់កណ្តាល ( ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា )*

ការងារសមាហរណកម្ម និង តាមដានជនរងគ្រោះជាភារកិច្ច របស់អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានសុខុមាលភាពសង្គម ដែលមានការិយាល័យប្រឆាំងការជួញដូរមនុស្ស និង សមាហរណកម្មជាសេនាធិកា ។ តួនាទី និងភារកិច្ចរបស់អ្នកសម្របសម្រួល និងការិ

យាល័យប្រឆាំងការជួញដូរមនុស្សនិងសមាហរណកម្ម និងមន្ត្រីទាំងអស់របស់ការិយាល័យនេះអនុវត្តតាមបទបញ្ជាជាធរមានរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ អ្នកសម្របសម្រួលត្រូវផ្តល់ការដឹកនាំជារួមដល់ការិយាល័យដែលទើបតែបង្កើតថ្មីនេះ និងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ។

អគ្គនាយកដ្ឋានបច្ចេកទេស ត្រូវបង្កើនការខិតខំស្វែងរកដៃគូអភិវឌ្ឍន៍នានា ដើម្បីផ្តល់ការគាំទ្រ និងជំនួយផ្សេងៗទាំងផ្នែកសំភារៈ និងថវិកាសម្រាប់អនុវត្តដំណើរការកម្មវិធីសមាហរណកម្ម និងតាមដាននៅគ្រប់ថ្នាក់។

ក្រៅពីនេះការងារសមាហរណកម្ម និងតាមដាន ត្រូវអនុវត្តតាមជាក់ស្តែងដូចខាងក្រោម :

***ក - ការប្រជុំសម្របសម្រួល***

- ណែនាំមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ក្រុង និងជួយដល់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម ខេត្ត ក្រុង ក្នុងការរៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ខេត្ត ក្រុង
- ប៉ាន់ប្រមាណលើជំនាញក្នុងការរៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ ខេត្ត ក្រុង របស់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម ខេត្ត ក្រុង ព្រមទាំងផ្តល់លទ្ធផលត្រឡប់ក្នុងន័យស្ថាបនា
- បញ្ជាក់ពីករណីដែលត្រូវបិទ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានយល់ព្រម ។

***ខ - ការត្រួតពិនិត្យ និង វាយតម្លៃ :***

- ត្រួតពិនិត្យ និងវាយតម្លៃតាមរយៈការពិនិត្យមើលសកម្មភាព ក្នុងរបាយការណ៍ប្រចាំខែ និងបញ្ជីនានា ដែលអង្គការមិនមែនរដ្ឋាភិបាលផ្តល់ឱ្យ
- ធ្វើការចុះពិនិត្យ និង តាមដានយ៉ាងទៀងទាត់ដល់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង និងមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ព្រមទាំងចុះដល់ផ្ទះជនដែលត្រូវធ្វើសមាហរណកម្ម
- បំពេញទម្រង់ត្រួតពិនិត្យ និង វាយតម្លៃរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងផ្តល់លទ្ធផលត្រឡប់ក្នុងន័យស្ថាបនា
- រៀបចំ និងសម្របសម្រួលកិច្ចប្រជុំបូកសរុបលទ្ធផលប្រចាំត្រីមាសនៅទីក្រុងភ្នំពេញ ជាមួយមន្ត្រីទទួលបន្ទុកនៅថ្នាក់ ខេត្ត ក្រុង និង បុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាលនានា ។

***គ - ការគ្រប់គ្រងករណី និងការសម្របសម្រួល***

- ធានាថា ទម្រង់ពាក់ព័ន្ធ ត្រូវបានប្រគល់ជូនមន្ត្រីទទួលបន្ទុកព័ត៌មាន និងទិន្នន័យបានទាន់ពេលវេលា
- ធានារក្សាការសម្ងាត់ឱ្យបានយ៉ាងខ្ជាប់ខ្ជួន ទាំងឯកសារសរសេរ និងការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់
- ជួយការងារទាំងឡាយណា ដែលនាយកដ្ឋានសុខុមាលភាពសង្គមបានចង្អុលបង្ហាញ
- ចូលរួមជាប្រចាំនូវរាល់ការប្រជុំជាមួយមន្ត្រីផ្សេងទៀតក្នុងការិយាល័យប្រឆាំងការជួញដូរមនុស្ស និង សមាហរណកម្ម ។

***ឃ - ការសហការសម្របសម្រួល***

- ទំនាក់ទំនងជាមួយបណ្តាអង្គការមិនមែនរដ្ឋាភិបាលនានា ដែលមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ និងសហការសម្របសម្រួលក្នុងករណីមានបញ្ហាជាមួយនឹងប្រព័ន្ធការងារវិមជ្ឈការ
- រៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយបណ្តាអង្គការមិនមែនរដ្ឋាភិបាលនានា ដែលមានទីតាំងនៅក្នុងក្រុងភ្នំពេញ ដើម្បីពិភាក្សាអំពីកត្តារាំងស្ទះនានា និងជោគជ័យនៅក្នុងការអនុវត្តកម្មវិធីសមាហរណកម្ម និងតាមដាន ។

***ង - ការងាររដ្ឋបាល***

- គ្រប់គ្រងឯកសារឱ្យបានល្អ
- បំពេញទម្រង់នានា តាមការបង្ហាញរបស់ក្រសួង ឬមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋា-ភិបាលនៅពេលចាំបាច់
- ធានាថា របាយការណ៍ផ្នែកហិរញ្ញវត្ថុត្រូវដាក់ជូនថ្នាក់ដឹកនាំក្រសួង និងអ្នកផ្តល់មូលនិធិទាន់ពេលវេលា ។

***ច - ប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងទិន្នន័យ***

- ធ្វើបច្ចុប្បន្នភាពសំណុំឯកសាររបាយការណ៍ប្រចាំខែ និងបញ្ជីនានា ដែលអង្គការមិនមែនរដ្ឋាភិបាលនានាបានផ្តល់ឱ្យ
- បង្កើត និងធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ នៅក្នុងម៉ាស៊ីនកុំព្យូទ័រអំពីជនដែលត្រូវធ្វើសមាហរណកម្ម ដែលបានធ្វើសមាហរណកម្មរួចហើយ ។
- រៀបចំរបាយការណ៍នៃការវិវឌ្ឍន៍ប្រចាំត្រីមាស និងប្រចាំឆ្នាំសម្រាប់ដាក់ជូនថ្នាក់ដឹកនាំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអ្នកផ្តល់មូលនិធិ ។

***៣-២-ថ្នាក់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង :***

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត ក្រុង នីមួយៗចាត់តាំងមន្ត្រី ០២ រូប ដែលធ្លាប់បានទទួលការបណ្តុះបណ្តាលសេវាសង្គមកិច្ចជាមូលដ្ឋាន និងសេវាសង្គមកិច្ចជំនាញ និងមានបទពិសោធន៍ការងារសមាហរណកម្ម និងតាមដាន ជាជនបង្គោលទទួលបន្ទុកសមាហរណកម្មខេត្ត ក្រុង ។ មន្ត្រី ០១ រូប ត្រូវជាថ្នាក់ដឹកនាំមន្ទីរនិង ០១ រូបទៀតជាប្រធានការិយាល័យសុខុមាលភាពសង្គម ឬ ជាមន្ត្រីទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម ។ ជនបង្គោលទាំង ០២ រូប នោះមានភារកិច្ចដូចខាងក្រោម :

***ក - ការសហការសម្របសម្រួល :***

- ជួយដល់អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលនានា ក្នុងការទំនាក់ទំនងជាមួយអាជ្ញាធរដែនដី
- ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងករណីមានបញ្ហា
- ទំនាក់ទំនង និងធ្វើរបាយការណ៍ជូនក្រសួង
- ជួយការងារទាំងឡាយណា ដែលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មបានចង្អុលបង្ហាញ
- ទំនាក់ទំនង ធ្វើការចងក្រងសៀវភៅធនធានក្នុង ខេត្ត ក្រុងរបស់ខ្លួន ។

***ខ - ការគ្រប់គ្រងករណី និង ប្រព័ន្ធព័ត៌មាន :***

- រៀបចំ និង ដឹកនាំកិច្ចប្រជុំសម្របសម្រួលថ្នាក់ខេត្ត ក្រុង

- ដឹកនាំនិងគ្រប់គ្រងមន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ក្នុងការរៀបចំផែនការនិងចុះពិនិត្យ និងតាមដានមុនពេលធ្វើសមាហរណកម្ម និងតាមដាន
- ទំនាក់ទំនងអំពីកាលបរិច្ឆេទ ពេលវេលា និងទីតាំងជួបគ្នាជាមួយបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ចាប់តាំងពីពេលមុនធ្វើសមាហរណកម្មតទៅ
- ជួយមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល និង មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ក្នុងការបញ្ជូនជនដែលត្រូវធ្វើសមាហ-រណកម្ម ទៅកាន់សេវាបណ្តុះបណ្តាលជំនាញ សាលារៀន សេវាវេជ្ជសាស្ត្រ ការគាំទ្រផ្នែកច្បាប់ ។ល។

### ***គ - ប្រព័ន្ធតាមដានត្រួតពិនិត្យ និងព័ត៌មានៈ***

- ធ្វើការតាមដាន និងត្រួតពិនិត្យវាយតម្លៃជាប្រចាំនៅការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ
- ធានាថា ការចំណាយផ្សេងៗត្រូវធ្វើឡើង សម្រាប់តែពេលធ្វើការពិនិត្យ និងតាមដានសកម្មភាពអនុវត្តជាក់ស្តែងតែប៉ុណ្ណោះ
- ធានាថាសំណុំឯកសាររបស់ជនដែលត្រូវធ្វើសមាហរណកម្ម ត្រូវបានថែរក្សាទុកយ៉ាងត្រឹមត្រូវ ហើយការចំណាយត្រូវធ្វើឡើងសម្រាប់ការតែតាមដានណា ដែលមានសំណុំឯកសារពេញលេញ
- ធានាថា មន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្រុក ខណ្ឌ បញ្ជូនរបាយការណ៍ប្រចាំខែមកទាន់ពេលវេលា
- ពិនិត្យផ្ទៀងផ្ទាត់លើខ្លឹមសាររបាយការណ៍ចំណាយ របាយការណ៍ប្រចាំខែ និងទម្រង់បិទករណី ទម្រង់ទី(៦ខ) និងឯកសារផ្សេងៗ ទៀត មុននឹងបញ្ជូនបន្តមកការិយាល័យប្រឆាំងការជួញដូរមនុស្ស និង សមាហរណកម្ម
- ធានាថា ទម្រង់ដែលចាំបាច់នានា និង របាយការណ៍ប្រចាំខែ ត្រូវបានដាក់បញ្ជូនមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ទាន់ពេលវេលា
- ធ្វើបច្ចុប្បន្នភាពសំណុំឯកសារករណី ដែលបានតាមដានក្នុង ខេត្ត ក្រុង តាមរយៈការរក្សាទុកនូវរបាយការណ៍ប្រចាំខែ ព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

### ***ឃ - ការប្រជុំសម្របសម្រួលៈ***

- រៀបចំ និង ដឹកនាំការប្រជុំសម្របសម្រួល និងបញ្ជាក់អំពីកាលបរិច្ឆេទ និងពេលវេលាសម្រាប់ការ ប្រជុំសម្របសម្រួលលើកក្រោយជាមួយអ្នកចូលរួម
- អញ្ជើញតំណាងមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាលនានា ស្ថាប័នពាក់ព័ន្ធ (មន្ទីរអប់រំយុវជន និងកីឡា សុខាភិ-បាល នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នគរបាលអន្តោប្រវេសន៍.....)។ល។ ដែលមានការពាក់ព័ន្ធ មកចូលរួម ក្នុងការប្រជុំសម្របសម្រួល
- សម្របសម្រួលការប្រជុំ ដើម្បីឱ្យសម្រេចបាននូវគោលបំណងរបស់ការប្រជុំនេះ
- សម្របសម្រួលផ្តល់ព័ត៌មានសំខាន់ៗ ទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ដើម្បីផ្តល់សេវាសុខុមាលភាពដល់ជនដែលត្រូវធ្វើសមាហរណកម្ម
- ប៉ាន់ប្រមាណពីគុណភាពការងាររបស់មន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ស្រុក ខណ្ឌ និងផ្តល់លទ្ធផលត្រឡប់ក្នុងន័យស្ថាបនា

- ដើរតួជាធនធានមួយសម្រាប់ការបញ្ជូនទៅរកសេវានានា តាមតម្រូវរបស់មន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ហើយសៀវភៅធនធានមានសារៈសំខាន់របស់តួនាទីនេះ
- ប្រសិនបើចាំបាច់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម ខេត្ត ក្រុង ត្រូវសម្របសម្រួលការបណ្តុះបណ្តាលបន្ថែមទៀតដល់មន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ
- ឆ្លើយតបនឹងលទ្ធផលត្រឡប់ ដែលមន្ត្រីរបស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និង សមាហរណកម្មទទួលបន្ទុកតាមតំបន់របស់ក្រសួងបានផ្តល់ឱ្យ
- ប្រសិនបើចាំបាច់ ជនបង្គោលទទួលបន្ទុកសមាហរណកម្ម ខេត្ត ក្រុង ត្រូវទទួលការបណ្តុះបណ្តាលបន្ថែមទៀតពីមន្ត្រីទទួលបន្ទុកតាមតំបន់របស់ក្រសួង
- បញ្ចេក់អំពីការបិទករណី ដោយផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យ ដែលបានយល់ព្រមជាមួយគ្នា ។

***៣-៣-ថ្នាក់ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ :***

មន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រុក ខណ្ឌ ត្រូវអនុវត្តភារកិច្ចដូចខាងក្រោមនេះ :

***ក - មុនពេលធ្វើសមាហរណកម្ម :***

- ជួយស្វែងរកគ្រួសារ របស់ជនដែលត្រូវធ្វើសមាហរណកម្ម តាមការណែនាំរបស់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង
- នៅពេលដែលរកឃើញគ្រួសាររបស់ជនដែលត្រូវធ្វើសមាហរណកម្ម ហើយត្រូវរាយការណ៍ព័ត៌មាននេះទៅឱ្យជនបង្គោលទទួលបន្ទុកសមាហរណកម ខេត្ត ក្រុង ដោយប្រើទម្រង់ស្វែងរកគ្រួសារ និងប៉ាន់ប្រមាណគ្រួសារ
- រៀបចំកម្មវិធីពិនិត្យ និងតាមដាន ដោយកំណត់អំពីពេលវេលា និងទីកន្លែងជាមួយនិងប្រធានភូមិ និងគ្រួសាររបស់ជនដែលត្រូវធ្វើសមាហរណកម្ម
- ត្រូវគោរពតាមពេលវេលាកំណត់ និងអមដំណើរជាមួយបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល និងជនដែលត្រូវធ្វើសមាហរណកម្មនៅពេលចុះពិនិត្យ និងតាមដានលើកដំបូង
- ធ្វើការពិនិត្យ និងតាមដាន ឱ្យបានច្រើនដងតាមការចាំបាច់ ដើម្បីប៉ាន់ប្រមាណស្ថានភាពគ្រួសារ និងផ្សះផ្សាគ្រួសារ។ បំពេញទម្រង់ស្វែងរកនិងប៉ាន់ប្រមាណគ្រួសារ រួចផ្ញើទៅជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង
- ធ្វើផែនការគាំទ្រផ្នែកសង្គមកិច្ច និងធ្វើការផ្សះផ្សាជាមួយជនដែលត្រូវធ្វើសមាហរណកម្ម គ្រួសារ និងសហគមន៍
- ធ្វើសមាហរណកម្ម នៅពេលដែលមានការព្រមព្រៀងគ្នារវាងជនដែលត្រូវធ្វើសមាហរណកម្មគ្រួសារ មជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរដែនដីរួចហើយ ។

***ខ - ការធ្វើសមាហរណកម្ម :***

- រៀបចំការណាត់ជួបគ្នា និងទៅទីកន្លែងដែលបានឯកភាពជាមួយបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាលឱ្យទាន់ពេលវេលា

- ត្រូវមានវត្តមាន ក្នុងអំឡុងពេលធ្វើសមាហរណកម្ម ដើម្បីធ្វើជាសាក្សី
- ផ្តួចផ្តើមធ្វើកិច្ចព្រមព្រៀងជាមួយគ្រួសារ និងជនដែលត្រូវធ្វើសមាហរណកម្ម ដោយគូសបញ្ជាក់ពីអំណាចមេបា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- សម្របសម្រួលទំនាក់ទំនងជាមួយអាជ្ញាធរផែនដី
- គោរពការរក្សាព័ត៌មានជាការសម្ងាត់ ដូចដែលបានព្រមព្រៀងគ្នាជាមុន
- រៀបចំបើកសំណុំឯកសារសម្រាប់ជនដែលត្រូវធ្វើសមាហរណកម្ម ដែលត្រូវបានធ្វើសមាហរណកម្មរួចហើយ សំណុំឯកសារនោះត្រូវមានទម្រង់សមាហរណកម្ម ទម្រង់ទទួល និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ប្រសិនបើមាន។

***គ - ការតាមដាន៖***

***+ ការតាមដានប្រភេទទី ១ ( ការតាមដានរួមគ្នា )៖***

- ធ្វើការពិនិត្យ និងតាមដានប្រចាំខែរួមគ្នាជាមួយបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល
- សហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាល
- វាយតម្លៃការវិវឌ្ឍន៍របស់ជនដែលត្រូវធ្វើសមាហរណកម្ម
- ស្វែងរកមូលនិធិ ដើម្បីផ្តល់ជំនួយដល់ជនដែលត្រូវធ្វើសមាហរណកម្ម ដែលត្រូវការជំនួយនេះ
- សម្របសម្រួលការផ្តល់ជំនួយផ្នែកច្បាប់ ឬវេជ្ជសាស្ត្រ និងបញ្ជូននៅពេលចាំបាច់
- ជួយក្នុងការបញ្ជូនជនដែលត្រូវធ្វើសមាហរណកម្មទៅសាលារៀន និងសម្របសម្រួលរកអាហារូបករណ៍
- ប្រមូលព័ត៌មានអំពីការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈ និង បញ្ជូនជនដែលត្រូវធ្វើសមាហរណកម្មទៅរកវគ្គបណ្តុះបណ្តាល
- ធ្វើកំណត់ត្រា ស្តីពីការពិនិត្យ និងតាមដាននិមួយៗ ដែលបានធ្វើជាមួយបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិ-បាល និងស្តីពីសេវាទាំងអស់ ដែលបានផ្តល់ឱ្យជនដែលត្រូវធ្វើសមាហរណកម្ម ។

***+ ការតាមដានប្រភេទទី ២ ( គ្មានវត្តមានរបស់បុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល )៖***

- ធ្វើការពិនិត្យ និងតាមដានប្រចាំខែទៅជនដែលត្រូវធ្វើសមាហរណកម្ម និងគ្រួសារដោយមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ ទៅតាមផែនការ
- ផ្តល់ការពិគ្រោះយោបល់ចិត្តសាស្ត្រសង្គមបន្ថែមដល់ជនដែលត្រូវធ្វើសមាហរណកម្ម
- វាយតម្លៃលើការអភិវឌ្ឍន៍របស់ជនដែលត្រូវធ្វើសមាហរណកម្ម
- ស្វែងរកមូលនិធិ ដើម្បីផ្តល់ជំនួយដល់ជនដែលត្រូវធ្វើសមាហរណកម្ម ដែលត្រូវការជំនួយនេះ
- សម្របសម្រួលការផ្តល់ជំនួយផ្នែកច្បាប់ ឬវេជ្ជសាស្ត្រ និងការបញ្ជូន នៅពេលចាំបាច់
- ជួយក្នុងការបញ្ជូនជនដែលត្រូវធ្វើសមាហរណកម្មទៅសាលារៀន និងសម្របសម្រួលរកអាហារូបករណ៍
- ប្រមូលព័ត៌មានអំពីការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈ និង បញ្ជូនជនដែលត្រូវធ្វើសមាហរណកម្មទៅរកវគ្គបណ្តុះបណ្តាល
- ធ្វើបច្ចុប្បន្នភាពកំណត់ត្រា ស្តីពីការពិនិត្យ និង តាមដាននិមួយៗ និងស្តីពីសេវាទាំងអស់ ដែលបានផ្តល់ឱ្យជនដែលត្រូវធ្វើសមាហរណកម្ម

- បំពេញទម្រង់ផ្តល់លទ្ធផលត្រឡប់ទៅមជ្ឈមណ្ឌលរបស់រដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាលហើយបញ្ជូនទម្រង់នេះ ទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង និងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្ម
- បិទករណី ដោយប្រើទម្រង់បិទករណី តែនៅពេលស្របតាមលក្ខណៈវិនិច្ឆ័យប៉ុណ្ណោះ ។

***ឃ - ការរាយការណ៍***

- ត្រូវផ្តល់របាយការណ៍ប្រចាំខែដល់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ។

***ង - ការប្រជុំសម្របសម្រួល***

- បង្ហាញយ៉ាងសង្ខេប ដល់អ្នកចូលរួមក្នុងការប្រជុំសម្របសម្រួលនេះ អំពីស្ថានភាពបច្ចុប្បន្ន របស់ករណីដ៏ស្មុគស្មាញបំផុតក្នុងចំណោមករណីទាំងអស់របស់ខ្លួនព្រមទាំងគ្រួសារ ជនដែលត្រូវធ្វើសមាហរណកម្ម ចាប់តាំងពីពេលធ្វើសមាហរណកម្មមក ( កំណត់ពីបញ្ហានានា និងជោគជ័យរបស់ករណីនីមួយៗ )
- កំណត់ពីប្រភេទសេវាគាំទ្រផ្នែកសង្គមកិច្ច ដែលបានផ្តល់ឱ្យជនដែលត្រូវធ្វើសមាហរណកម្ម ព្រមទាំងគ្រួសារ ចាប់តាំងពីពេលធ្វើសមាហរណកម្ម
- កំណត់ពីបញ្ហានានា ដែលជួបប្រទះនៅក្នុងការតាមដានជនដែលត្រូវធ្វើសមាហរណកម្មដែលបានធ្វើសមាហរណកម្មរួច
- កំណត់រកជំហ៊ានដែលត្រូវអនុវត្ត ដើម្បីបង្កើនភាពជោគជ័យ នៃការធ្វើសមាហរណកម្ម របស់ជនដែលត្រូវធ្វើសមាហរណកម្មម្តងៗ
- ឆ្លើយតបយ៉ាងវិជ្ជមានចំពោះមតិយោបល់របស់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង និងអ្នកចូលរួមប្រជុំ
- ករណីចាំបាច់មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ត្រូវទទួលជំនួយបច្ចេកទេសបន្ថែមទៀតពីមន្ត្រីទទួលបន្ទុកបណ្តុះបណ្តាលថ្នាក់ជាតិ
- កំណត់ពីករណីនានា ដែលត្រូវបិទ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបិទករណី។

## ៤ ~ តួនាទី និងការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាលនានា :

មជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលអនុវត្តកម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមមណ្ឌល ត្រូវមានការទទួលខុសត្រូវមួយចំនួនពាក់ព័ន្ធនឹងកម្មវិធីនេះ :

***ក - ព័ត៌មាន :***

- ផ្តល់តារាងឈ្មោះជនដែលត្រូវធ្វើសមាហរណកម្ម ដែលបានធ្វើសមាហរណកម្មរួចដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅរៀងរាល់ចុងខែ ។

***ខ - មុនពេលធ្វើសមាហរណកម្ម :***

- ទំនាក់ទំនងជាមួយជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ដើម្បីសុំជំនួយក្នុងការស្វែងរកគ្រួសារជនដែលត្រូវធ្វើសមាហរណកម្ម

- នៅពេលទទួលដំណឹង អំពីការរកឃើញគ្រួសាររបស់ជនដែលត្រូវធ្វើសមាហរណកម្មហើយ ត្រូវរៀបចំចុះពិនិត្យ និងតាមដាន ទៅគ្រួសាររបស់ជនដែលត្រូវធ្វើសមាហរណកម្ម តាមរយៈជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង
- ចុះពិនិត្យ និងតាមដានលើគ្រួសារជនដែលត្រូវធ្វើសមាហរណកម្មជាមួយមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ដើម្បីចាប់ផ្តើមដំណើរការ ប៉ាន់ប្រមាណ និងផ្សះផ្សា
- សម្រេចឱ្យបានការព្រមព្រៀងគ្នារវាងជនដែលត្រូវធ្វើសមាហរណកម្មគ្រួសារ មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអាជ្ញាធរមូលដ្ឋាន ដោយធ្វើផែនការគាំទ្រផ្នែកសង្គមកិច្ច និងឈានទៅរកការធ្វើសមាហរណកម្ម ។

***គ - ការធ្វើសមាហរណកម្ម :***

- ជូនដំណឹងដល់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង អំពីការធ្វើសមាហរណកម្មទៅតាមពេលវេលា ដែលបានព្រមព្រៀងគ្នា
- ផ្តល់ព័ត៌មានអំពីជនដែលត្រូវធ្វើសមាហរណកម្ម ដើម្បីឱ្យមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ អាចបើកសំណុំឯកសារករណីបាន
- ជួយមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ លើការងារសំណុំឯកសារករណីនៅពេលចាំបាច់ ។

***ឃ - ការតាមដានរួមគ្នា ( ការតាមដានប្រភេទទី ១ ) :***

- បញ្ជាក់ឡើងវិញជាមួយជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង អំពីកាលបរិច្ឆេទ និងទីកន្លែងចុះតាមដាន
- ជូនដំណឹងដល់ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង អំពីការផ្លាស់ប្តូរពេលវេលាចុះតាមដាន ដើម្បីជៀសវាងការធ្វើដំណើរមិនចាំបាច់របស់មន្ត្រី
- ធ្វើការពិនិត្យ និងតាមដានរួមគ្នាជាមួយមន្ត្រីសង្គមកិច្ច ស្រុក ខណ្ឌ
- ជួយមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ក្នុងការវាយតម្លៃការវិវឌ្ឍរបស់ជនដែលត្រូវធ្វើសមាហរណកម្ម
- ជួយមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ក្នុងការបញ្ជូន និងការកំណត់រកប្រព័ន្ធគាំទ្រនានា
- ផ្តល់ព័ត៌មានបន្ថែមទៀតដល់មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ដើម្បីធានាថាសំណុំឯកសារករណីមាន សុក្រិតភាព ។

❖ **ការចុះតាមដានដោយគ្មានវត្តមានបុគ្គលិកមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាលនានា ( ការតាមដានប្រភេទទី ២ ) :**

- ឆ្លើយតបទៅនឹងអនុសាសន៍ដែលផ្តល់នៅក្នុងទម្រង់ ផ្តល់លទ្ធផលត្រឡប់ទៅមជ្ឈមណ្ឌលរបស់រដ្ឋ ឬ អង្គការមិនមែនរដ្ឋាភិបាល ដោយធ្វើទំនាក់ទំនងជាមួយមន្ត្រីទទួលបន្ទុក របស់ក្រសួងនៅថ្នាក់កណ្តាល ឬ ជនបង្គោលទទួលបន្ទុកសមាហរណកម្ម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង។
- ធានាថា ត្រូវចាត់វិធានការចុះតាមដាន ប្រសិនបើចាំបាច់ ហើយត្រូវផ្តល់ព័ត៌មាន អំពីវិធានការចុះតាមដាននេះ ឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ដើម្បីសម្រួលដល់ការអនុវត្តជាក់ស្តែង តាមសារាចរណែនាំនេះ ក្រសួងមានទម្រង់ចំនួន ០៧ និងទម្រង់ករណីពិសេសចំនួន ០២ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ :

***ក - ទម្រង់ទាំង ៧***

- ទម្រង់ទី ១ : ទម្រង់ទទួលជនដែលត្រូវធ្វើសមាហរណកម្ម និងស្វែងរកគ្រួសារ
- ទម្រង់ទី ២ : ទម្រង់ប៉ាន់ប្រមាណគ្រួសារ
- ទម្រង់ទី ៣ : ទម្រង់ផែនការករណី
- ទម្រង់ទី ៤ : ទម្រង់សមាហរណកម្ម
- ទម្រង់ទី ៥ : ទម្រង់តាមដាន
- ទម្រង់ទី ៦ ក : ទម្រង់បញ្ជូនទៅរកសេវា
- ទម្រង់ទី ៦ ខ : ព័ត៌មានត្រឡប់ទៅអង្គការ
- ទម្រង់ទី៧ : ទម្រង់បិទករណី

***ខ - ទម្រង់ករណីពិសេស***

- ទម្រង់ករណីពិសេសទី ១ : ការសម្ភាសន៍ទទួលជនដែលត្រូវធ្វើសមាហរណកម្ម
- ទម្រង់ករណីពិសេសទី ២ : ការប៉ាន់ប្រមាណគ្រួសារ

គ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង អង្គការមិនមែនរដ្ឋាភិបាលនានា ដែលមានការពាក់ព័ន្ធមានភារកិច្ចសហការអនុវត្តសារាចរណែនាំនេះឱ្យទទួលបានលទ្ធផលល្អប្រសើរ ។

**រដ្ឋមន្ត្រី**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
- គ្រប់សាលាខេត្ត ក្រុង
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- គ្រប់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ
- ឯកសារ - កាលប្បវត្តិ